ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ MINISTRY OF ECONOMY AND FINANCE

គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ១ ចេញផ្សាយថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១
No. 1 Released on July 6, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# សេចក្តីសង្ខេបនៃប្រវត្តិច្បាប់ស្តីពីបរធនបាលកិច្ច

## A Summary of Trust Law History



រូបភាព | Picture:
https://upload.wikimedia.org/wikipedia/commons/d/d9/Court_of_Chancery_edited.jpg

ច្បាប់ស្តីពីបរធនបាលកិច្ចដំបូង មានប្រវត្តិនៅចក្រភពអង់គ្លេស ដែលច្បាប់នេះត្រូវបានបង្កើតឡើងនៅសតវត្សរ៍ទី ១២ ចាប់ពីពេលបូជ-នីយកិច្ចក្រោមយុត្តាធិការរបស់ព្រះមហាក្សត្រអង់គ្លេស ("History of Equity and Trusts," 2020; Panesar, 2017)។ ប្រវត្តិក្នុងការបង្កើតច្បាប់នេះ ជាប់ពាក់ព័ន្ធនឹងភាពជាកម្មសិទ្ធិលើដីធ្លី។ រឿងរ៉ាវបានកើតឡើងនៅពេលម្ចាស់ដីជាច្រើនត្រូវចាកចេញពីប្រទេសអង់គ្លេស ដើម្បីទៅធ្វើសង្គ្រាមក្នុងបូជនីយកិច្ចរបស់ពួកគាត់។ ក្នុងពេលអវត្តមាននោះ ពួកគាត់បានប្រគល់ដីឱ្យលោកម្ចាស់អធិការបតី ដែលមានសិទ្ធិគ្រប់គ្រងដី ហើយត្រូវប្រគល់ដីមកឱ្យពួកគាត់វិញពេលត្រឡប់មកពីធ្វើសង្គ្រាម។ ក៏ប៉ុន្តែ ក្រុមបូជនីយកិច្ចតែងតែជួបប្រទះការបដិសេធពីលោកម្ចាស់អធិការបតីដែលមិនព្រមប្រគល់ដីនៅពេលពួកគេត្រឡប់មកវិញ។ ជាអកុសលសម្រាប់ក្រុមបូជនីយកិច្ច ប្រព័ន្ធច្បាប់របស់អង់គ្លេសនៅពេលនោះ មិនបានទទួលស្គាល់ការអះអាងរបស់គាត់ទេ។ តុលាការយល់ថាដីទាំងនោះ គឺជាកម្មសិទ្ធិរបស់អ្នកទទួលខុសត្រូវលើដីដែលគ្មានកាតព្វកិច្ចត្រូវប្រគល់ដីនោះមកវិញទេ។ ក្រុមបូជនីយកិច្ចគ្មានសិទ្ធិទាមទារស្របតាមផ្លូវច្បាប់ទេ។ នៅពេលនោះ មានលោកម្ចាស់អធិការបតីសប្បុរសម្នាក់ បានសម្រេចរឿងក្តីទៅតាមមនសិការរបស់លោក ដោយលោកចាត់ទុកថាវាជាការមិនត្រឹមត្រូវទេ ដែលអ្នកថែរក្សាដីបដិសេធមិនព្រមប្រគល់ដី ឱ្យទៅម្ចាស់ដីដែលជាក្រុមបូជនីយកិច្ចវិញ។ ចាប់ពីពេលនោះមក តុលាការរបស់លោកម្ចាស់អធិការបតី តែងទទួលស្គាល់ជានិច្ចនូវការទាមទាររបស់ក្រុមបូជនីយកិច្ច ដែលវិលត្រឡប់មកពីធ្វើសង្គ្រាមវិញ ហើយបុគ្គលកាន់កាប់ដី ដើម្បីជាប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិដីដើមត្រូវប្រគល់ដីឱ្យទៅម្ចាស់ដើមវិញនៅពេលមានការស្នើសុំ ("History of Equity and Trusts," 2020; Panesar, 2017)។

The first development of trust law was in the 12th century in the UK after the Crusades under the jurisdiction of the British monarch ("History of Equity and Trusts," 2020; Panesar, 2017). The history of this law is related to the ownership of the land. It happened when many landowners had to leave England to go to war in their crusades. In their absence, they handed over the land to the Chancellor, who had the right to manage the land, and had to return the land to them when they returned from the war. However, the crusaders often faced rejection from the chancellor who refused to return the land when they returned. Unfortunately for the crusades, the UK's common law at that time did not recognize their claims. The court found that the land belonged to the person in charge of the land and there was no obligation to return it. The crusades had no legal claim. At that time, a kind-hearted chancellor decided the case according to his conscience, considering that it was not right for the land keeper to refuse to return the land to the crusaders. Since then, the court of the chancellor had always recognized the claims of the crusaders returning from the war, and the person holding the land for the benefit of the original land owner must return the land to its original owner when requested ("History of Equity and Trusts," 2020; Panesar, 2017).

**ឯកសារយោង | References**:

- Panesar, S. (2017). Equity and Trusts (3th ed.). Pearson
- History of equity and trusts. (2020). In Wikipedia. https://en.wikipedia.org/w/index.php?title=History_of_equity_and_trusts&oldid=99309882

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.